**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត**

លេខ ៤២៥/១៦ គ.ជ.ប

# សេចក្តីជូនដំណឹង

គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត (គ.ជ.ប) សូមជម្រាបជូនសាធារណជនឱ្យបានជ្រាបថា គ.ជ.ប ត្រូវការជ្រើសរើសក្រុមចុះឈ្មោះបោះឆ្នោត (ក.ច.ប) ចំនួន ១.៦៣៣ ក្រុម ស្មើនឹង ចំនួន ៦.១០៣ នាក់ ជាមន្ត្រីជាប់កិច្ចសន្យារយៈពេលខ្លី ដើម្បីបម្រើការងារនៅតាមឃុំ សង្កាត់ នៃរាជធានី ខេត្ត សម្រាប់ការចុះឈ្មោះបោះឆ្នោត ដើម្បីរៀបចំបញ្ជីបោះឆ្នោតថ្មី ឆ្នាំ២០១៦ ដែលមានមុខតំណែងដូចខាងក្រោម ៖

១- ប្រធានក្រុមចុះឈ្មោះបោះឆ្នោត (ក.ច.ប)

២- សមាជិក ក.ច.ប ជាជំនួយការអនុប្រធាន

៣- សមាជិក ក.ច.ប ជាការីកុំព្យូទ័រ

បេក្ខជនដែលមានបំណងដាក់ពាក្យសុំបម្រើការងារតាមមុខតំណែងខាងលើ សូមអញ្ជើញទៅមើលសេចក្តីជូនដំណឹងស្តីពីការជ្រើសរើស ស្តីពីការដាក់ពាក្យសុំបម្រើការងារ ស្តីពីលក្ខខណ្ឌជ្រើសរើស និងការដាក់ពាក្យ ការទទួលពាក្យ ដែលនឹងបិទផ្សាយចាប់ពីថ្ងៃទី២៦ ខែកក្កដា ឆ្នាំ២០១៦ នៅតាមសាលាឃុំ សង្កាត់ និងទីកន្លែងសាធារណៈក្នុងឃុំ សង្កាត់ ដែល គ.ជ.ប បានកំណត់ ។

ពាក្យសុំចូលបម្រើការងារនឹងមានចែកជូននៅតាមសាលាឃុំ សង្កាត់ ដោយឥតគិតថ្លៃ ។

- ការចាប់ផ្តើមទទួលពាក្យនៅ ថ្ងៃទី០៥ ខែសីហា ឆ្នាំ២០១៦ (វេលាម៉ោង៧:០០ព្រឹក) ។
- ការឈប់ទទួលពាក្យនៅ ថ្ងៃទី០៩ ខែសីហា ឆ្នាំ២០១៦ (វេលាម៉ោង១៧:៣០ល្ងាច) ។

រាជធានីភ្នំពេញ ថ្ងៃទី ២៦ ខែ កក្កដា ឆ្នាំ២០១៦

**ជ.គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត**

**ប្រធាន**

**ស៊ិក ប៊ុនហុក**